ណែនាំរបស់ប្រធាន ហើយរៀបចំកម្មវិធីទៀងទាត់ ដើម្បីរួមគណៈឧិកនាទីស្ដីការ គណៈរដ្ឋមន្ត្រី ។

ប្រការ ៤ : ក្រុមការងារនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកជំនាញ និង ទីប្រឹក្សា មានការ ៤ ដើម្បីមកពិភាក្សា អំពីធនធានសម្ព័ន្ធរដ្ឋបាល របស់ក្រសួង និងស្ថាប័ន និមួយ' តាមការចាំបាច់ នៃករណីជាក់ស្ដែងនិមួយៗ ។

ប្រការ ៥ : ក្រុមការងារនេះ នឹង ត្រូវរំសាយដោយស្វ័យប្រវត្តិ នៅពេលដែលធនធានសម្ព័ន្ធ រដ្ឋបាល ទូទាំងប្រទេស ត្រូវបានកែប្រែជាស្ថាពរហើយ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីមុខងារសាធារណៈ រដ្ឋមន្ត្រី និង ប្រធាន ក្រសួង ស្ថាប័ននានា និង សាមីខ្លួន ដែលមានការងារនាមក្នុងប្រការ ១ ត្រូវ អនុវត្តសេចក្ដីសំរេចនេះ ។

ប្រការ ៧ : សេចក្ដីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

សហប្រធាន ក ជ ន

ស ខេង

* * *

ភ្នំពេញ , ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្ដីសំរេច លេខ ១៨ សសរ

### ស្ដីពីការបង្កើតគណៈកម្មការទទួលអំណោយរៀបចំ អនាម័យ និង កែលំអសោភ័ណភាពទីក្រុងភ្នំពេញ

* * *

### រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យ ស្ដីពីការតែងតាំងរដ្ឋាភិបាលបណ្ដោះអាសន្ន នៃកម្ពុជា របស់សម្ដេច ព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃ កម្ពុជា ចុះថ្ងៃទី ០២ នៃ កក្កដា ឆ្នាំ១៩៩៣

- បានឃើញតម្រូវការចាំបាច់ នៃការងាររៀបចំ អនាម័យកែលំអទីក្រុងភ្នំពេញ

## សំរេច

ប្រការ ១ ៖ បង្កើតគណៈកម្មការទទួលអំណោយរៀបចំ អនាម័យ និង កែលំអសោភ័ណភាពទីក្រុងភ្នំពេញ ដែលមានសមាសភាពដូចតទៅ ៖

១- ឯកឧត្តម សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហប្រធាន
២- ឯកឧត្តម វេង សេរីវុឌ្ឍ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហប្រធាន
៣- ឯកឧត្តម ការ ហ៊ុត រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុប្រធាន
៤- ឯកឧត្តម ហុង ស៊ុនហួត រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក
៥- ឯកឧត្តម ត្រាំ អ៊ីវតឹក អនុរដ្ឋមន្ត្រីក្រសួងសាធារណការ សមាជិក
៦- ឯកឧត្តម ម៉ម សុផាណា ទីប្រឹក្សាអមឯកឧត្តមសហប្រធាន សមាជិក
៧- ឯកឧត្តម ត្រឹយ៍ ប៉េងហុង អភិបាលរងទីក្រុងភ្នំពេញ សមាជិក
៨- ឯកឧត្តម លី ឡាយស្រេង អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ហិរញ្ញិក

ប្រការ ២ ៖ គណៈកម្មការមានភារកិច្ច

១- អំពាវនាវ ដល់ស្ថាប័នរដ្ឋ អាជីវករ ពាណិជ្ជករ សិប្បករ និង ប្រជាពលរដ្ឋក្នុងទីក្រុងភ្នំពេញអោយចូលរួមវិភាគទានក្នុងគោលដៅខាងលើ ។

២- ចលនាសុំអំណោយពីសប្បុរសជន ។

៣- ចេញលិខិតថ្លែងអំណរគុណដល់សប្បុរសជនដែលបានផ្តល់នូវអំណោយ ។

៤- ចេញលិខិតថ្លែងអំណរគុណដែលឡាយព្រះហស្ថ និង ចុះហត្ថលេខាដោយសហប្រធាន នៃរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា ចំពោះអំណោយដែលមានតំលៃស្មើ ឬ លើសពី ៥ ០០០ ដុល្លារអាមេរិក ។

៥- តាមដានត្រួតពិនិត្យការប្រើប្រាស់ នូវអំណោយ និង ធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារអនុវត្ត ជូនរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ។

ប្រការ ៣ ៖ គណៈកម្មការនេះ ត្រូវចូលរួមប្រជុំ តាមសេចក្តីអញ្ជើញនិង ការណែនាំពីសហប្រធាន ។

ប្រការ ៤ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មរដ្ឋមន្ត្រី

ក្រុងភ្នំពេញ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ។

សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

ភ្នំពេញ, ថ្ងៃទី ១៤ ខែ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ១៩ សសរ

## ស្តីពីការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សំរាប់និតិសម្បទា និង អភិវឌ្ឍន៍ នៃប្រទេសកម្ពុជា

* * *

### រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- បានឃើញសេចក្តីសំរេចរបស់រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា ស្តីពីការបង្កើតគណៈកម្មាធិការជាតិសំរាប់និតិសម្បទា និងអភិវឌ្ឍន៍ ( ហៅកាត់ថា គ ជ នា ) នៃប្រទេសកម្ពុជា លេខ ០៨ សសរ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៣
- តាមសំណើរបស់ គ ជ នា